# ការសំភាសន៍របស់ អ៊ុំ ស្រីដែត

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ អ៊ុំ ស្រីដែត

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYUហាសបង សាលាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងដូនតាហាសបង នៅពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង តើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែររឺទេបង?

ខៈ ចាបានតា

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍បងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី27 ខែ1 ឆ្នាំ2018 ហើយការសំភាសន៍នេះត្រូវបានធ្វើនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញហាសបង បាទចឹងសំរាប់បងឈ្មោះពេញរបស់បងមានឈ្មោះអីគេដែរបង?

ខៈ ខ្ញុំឈ្មោះអ៊ុំ ស្រីដែត

កៈ ចុះមានឈ្មោះហៅក្រៅទេបង?

ខៈ អត់មានទេមានឈ្មោះតែមួយទេ

កៈ ចុះកាលពីក្មេងមាននរណាហៅឈ្មោះបងអីផ្សេងទេបង?

ខៈ អត់ទេមានតែឈ្មោះមួយនឹងឯង

កៈ ចុះសំរាប់បងសព្វថ្ងៃអាយុប៉ុន្មានដែរបង?

ខៈ ខ្ញុំអាយុ35ឆ្នាំ

កៈ អាយុ35ឆ្នាំ ចុះបងកើតនៅថ្ងៃខែឆ្នាំណាបងមានចងចាំទេ?

ខៈ ខ្ញុំមិនសូវដឹងទេ ខ្ញុំដឹងថាខាងចុងឆ្នាំ1983 ខ្ញុំដឹងតែឆ្នាំច

កៈ ចឹងបងកើតនៅឆ្នាំ1983ណាបង?

ខៈ នឹងមានតែនឹងទេ

កៈ ចុះឆ្នាំខ្មែរបងឆ្នាំច ណាបង?

ខៈ ខ្ញុំឆ្នាំច

កៈ ចុះបងកើតនៅណាដែរបង ដូចជានៅភូមិអី ឃុំអី ស្រុកអី ខេត្តអីបង?

ខៈ ខ្ញុំកើតនៅនឹងតា ខ្ញុំកើតនៅភ្នំពេញនឹងតា

កៈ ចឹងបងកើតនៅនឹងតែម្ដងហោសបង កើតនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញនឹងតែម្ដងណាហោសបង?

ខៈ អត់ទេខ្ញុំមិនមែនកើតនៅភូមិ4នឹងទេ និយាយរួមទៅខ្ញុំកើតនៅលើទូកទេ នៅមុខវាំងគេបណ្ដែតតាមទឹកហាស ខ្ញុំកើតនៅមុខវាំងទេខ្ញុំមិនមែនកើតនៅនឹងទេ

កៈ ចឹងបងមិនដឹងថាបងនៅណុងភូមិអីគេទេណាបង?

ខៈ ខ្ញុំអត់ដឹងទេខ្ញុំកើតនៅលើទូកនឹងមិនដឹងគេហៅស្អីទេ

កៈ បាទចឹងបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខៈ ខ្ញុំមានបងប្អូន12នាក់

កៈ អូច្រើនចុះបងជាកូនទីប៉ុន្មានដែរបង?

ខៈ ខ្ញុំបែបកូនទី4ហើយ

កៈ ចុះបងមានស្រីប៉ុន្មាន នឹងប្រុសប៉ុន្មាននាក់បងមានចងចាំទេ?

ខៈ ប្រុស9នាក់ ស្រី3នាក់

កៈ ចុះបងអាចប្រាប់ឈ្មោះបងប្អូនរបស់បងបានទេបង?

ខ៖ បើនិយាយរួមទៅស្លាប់អស់ប៉ុន្មាននាក់ដែរនឹង
នៅសល់តែមើលឈ្មោះបងរបស់ខ្ញុំឈ្មោះ អ៊ុំ សុខ ឌឿន,

ក៖ នឹងកូនទីប៉ុន្មានដែរបង?

ខ៖ នឹងកូនបន្ទាប់ទេបងៗៗមុនស្លាប់បាត់អស់ហើយខ្ញុំមិនដឹងទេ

ក៖ អូកូនបន្ទាប់ៗទេហោសបង?

ខ៖ ឈ្មោះអ៊ុំ សុខ ឌឿន, អ៊ុំសុខ ដេត, អ៊ុំ ចន្ថា
ខ្ញុំកូនទី3នឹងនិយាយខ្ញុំថាអត់និយាយអ្នកស្លាប់ទេណា នឹងឈ្មោះ អ៊ុំ ចំរើន, នឹងអ៊ុំ សុខដន,
នឹងអ៊ុំ លក្ខិណា, អ៊ុំ សុវណ្ណី, អ៊ុំ សុវណ្ណារ៉ា, អ៊ុំ សុវណ្ណារិទ្ធ ហើយនឹងទេភ្លេចអស់ហើយនឹង
និយាយចឹង ឈ្មោះ អ៊ុំ សុវណ្ណី , អ៊ុំសុវណ្ណារ៉ា អានឹងពៅគេហើយនឹងហោស

ក៖ ចឹងដូចជាមានស្លាប់ប្រហែលជាប៉ុន្មាននាក់ដែរបង នឹងនៅរស់ប៉ុន្មាននាក់ដែរបង?

ខ៖ ដូចជាស្លាប់3-4នាក់ហើយនេះ នៅរស់ប្រហែលជា9នាក់ហើយនឹង

ក៖ អូនៅរស់ប្រហែលជា9នាក់ហោសបង
ចុះបងមានចងចាំសាច់រឿងអីកាលពីនៅក្មេងជាមួយពួកគាត់ដែរទេបង
ដូចជាបងធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់ហាស?

ខ៖ ពីកាលខ្ញុំនៅក្មេងនឹងបងខ្ញុំស្លាប់អស់ហើយ

ក៖ ដូចជាបងប្អូនរបស់បងដែររស់នៅ8-9នាក់ដែរបងរៀបរាប់មិញនឹងបង?

ខ៖ ខ្ញុំគ្មានរឿងអីទេមានតែរត់ម៉ូតូឌុប

ក៖
អត់ទេបងកាលពីបងនៅក្មេងៗហាសបងតមានធ្លាប់លេងអីជាមួយពួកគាត់ទេដូចជាលេង
ឡឹកបាយឡ លេងងីចឹងហាស?

ខ៖ អូខ្ញុំគ្មានលេងអីទេមានតែនៅផ្ទះនឹងបងប្រុសៗរបស់ខ្ញុំនឹង

ក៖ ចុះបងមានដែរដើរលេងអីជាមួយពួកគាត់ដែរទេ?

ខ៖ អត់ដែរដើរទេនិយាយរួមទៅខ្ញុំធ្លាប់តែលក់បន្លែទេកាលខ្ញុំអាយុ13-14ឆ្នាំខ្ញុំនៅលក់បន្លែទេ ខ្ញុំយកទៅលក់នៅផ្សារចាស់នឹង មានតែខ្ញុំទេបានតស៊ូ បើបងៗរបស់ខ្ញុំអត់សូវតស៊ូដូចខ្ញុំទេ ពួកគាត់មានធ្វើអីទេពួកគាត់ដើរតែលេងនឹង

ក៖ ចុះកាលពីក្មេងបងចូលចិត្តធ្វើអីគេជាមួយបងប្អូនរបស់បងដែរ?

ខ៖ អូខ្ញុំអត់ទេខ្ញុំខុសគេ ខ្ញុំមានតែលក់បន្លែនឹងលក់បន្លុកទេ

ក៖ ចុះបងអត់ដែរធ្វើអីជាមួយបងប្អូនទេណាបង?

ខ៖ អត់ដែរធ្វើអីទេ បងរបស់ខ្ញុំអត់ដែរមានធ្វើអីទេ ខ្ញុំលក់តែបន្លែទេតាំងពីខ្ញុំបានអាយុ16-17ឆ្នាំនឹង

ក៖ ចុះបងប្អូនរបស់បងសព្វថ្ងៃគាត់រស់នៅណាដែរបង?

ខ៖ អូគាត់នៅឆ្ងាយពីខ្ញុំ

ក៖ ចុះគាត់រស់នៅខេត្តណាខ្លះទៅបង?

ខ៖ ខ្លះរស់នៅខេត្តកំពង់ឆ្នាំង ខ្លះរស់នៅព្រៃករកា ហើយខ្លះរស់នៅខេត្តស្វាយរៀង តែខ្ញុំទេដែររស់នៅភ្នំពេញនឹង

ក៖ អូបាទបងចុះពួកគាត់ថ្វើអីគេដែរបងនៅព្រៃករកានឹង?

ខ៖ គាត់រត់ម៉ូតូឌុបនឹង

ក៖ នឹងនៅណានៅភ្នំពេញហោសបង?

ខ៖ បើនិយាយអោយចំទៅប្អូនរបស់ខ្ញុំនៅស្វាយរៀងវាធ្វើសំណង់ ក្រៅពីនឹងរតើម៉ូតូឌុបទេ

ក៖ នឹងជាមួយបងប្អូនរបស់បងប៉ុន្តែជាក្រុមគ្រួសារមែនទេបងរត់ម៉ូតូឌុបនឹង?

ខ៖ នឹងគេមានគ្រួសារអស់ហើយនឹង

ក៖ ប៉ុន្តែគេចិញ្ចឹមគ្រួសាររបស់គេណាបង?

ខ៖ នឹងគ្រួសាររបស់គេ យើងវាបែកអស់ហើយនឹង

ក៖ ចឹងមានន័យថាប្អូនពៅរបស់បងក៏រៀបការហើយដែរ?

ខ៖ ប្អូនពៅរបស់បងនៅកំលោះទេមិនធ្វើអីទេ គ្នានៅផ្ទះទេ

ក៖ មានប៉ុន្មាននាក់ដែររៀបការហើយ មានប៉ុន្មាននាក់ដែរនៅបង?

ខ៖ និយាយអោយចំទៅការនឹងស្លាប់អស់ម្នាក់ហើយនឹង ស្លាប់អាបន្ទាប់ពៅ

ក៖ ស្លាបតែម្នាក់ទេក្រៅពីនឹងនៅទាំងអស់គ្នា?

ខ៖ ស្លាប់តែអាបន្ទាប់ពៅម្នាក់ទេក្រៅពីនឹងបងៗខ្ញុំកើតមិនទាន់ទេ ប៉ុន្តែអាពៅរបស់ខ្ញុំនៅកំលោះទេ ក្រៅពីនឹងពួកគេមានគ្រួសារអស់ហើយនឹង

ក៖ ចុះម្តាយរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ កួន ងាត់

ក៖ ចុះគាត់អាយុប៉ុន្មានដែរបង?

ខ៖ ម្តាយរបស់ខ្ញុំគាត់អាយុជិត50ឆ្នាំនឹង

ក៖ ប៉ុន្តែគាត់នៅទេ?

ខ៖ គាត់នៅរស់តា តែឪពុករបស់ខ្ញុំគាត់ស្លាប់បាត់ហើយនឹង

ក៖ គាត់អាយុ49ឆ្នាំណបង ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាបងមានដឹងទេ?

ខ៖ អូអត់ដឹងទេ មិនដែរបានមើលថ្ងៃខែកំណើតគាត់ផងនឹង

ក៖ ម្តាយរបស់បងគាត់កើតនៅឆ្នាំ1969បង?

ខ៖ នឹងហើយពីព្រោះអីគាត់អាយុ48-49ឆ្នាំហើយនឹង

ក៖ ចុះគាត់កើតនៅភូមិអី ឃុំអីបងមានចងចាំទេ?

ខ៖ គាត់នៅកន្ទួត សៀមរាប

ក៖ គាត់នៅកន្ទួត សៀមរាបណបង ចុះគាត់ឆ្នាំច័ន្ទគតិគាត់ឆ្នាំអីគេដែរបងមានដឹងទេ?

ខ៖ បងវាមិនដឹងទេ បងគ្រាន់តែដឹងថាគាត់អាយុ48-49ឆ្នាំទេ

ក៖ អូបាទបង ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ ឪពុករបស់បងគាត់មានឈ្មោះ អ៊ុំ សុខជា

ក៖ ឈ្មោះ អ៊ុំ សុខជា ចុះគាត់អាយុប៉ុន្មានដែរបងមានដឹងទេ?

ខ៖ អូគាត់អាយុ50ឆ្នាំជាងហើយនឹង

ក៖ គាត់អាយុនហាប៉ុន្មានដែរទៅបងចាំទេ?

ខ៖ គាត់ប្រហែលជាអាយុ53-54ឆ្នាំហើយ

ក៖ គាត់អាយុ54ឆ្នាំណាបង?

ខ៖ ចានឹងហើយ

ក៖ ចឹងគាត់កើតនៅឆ្នាំ1964ឆ្នាំបង

ខ៖ គាត់អាយុ54ឆ្នាំហើយប៉ានោះ

ក៖ ប៉ុន្តែគាត់កើតនៅណាបងមានដឹងទេ?

ខ៖ គាត់កើតនៅខេត្តកំពង់ចាម គាត់នៅព្រៃករកា កំពង់ចាម

ក៖ ចឹងមានន័យថាគាត់នៅទីរួមខេត្តណាបង?

ខ៖ ចាគាត់អ្នកទីរយមខេត្ត

ក៖ ចុះឪពុករបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមក្រុមគ្រួសារដែរបង?

ខ៖ គាត់រត់ម៉ូតូឌុប

ក៖ គាត់រត់តែម៉ូតូឌុបតែមួយទេណាបង?

ខ៖ ចារត់ម៉ូតូឌុបនឹងឯង

ក៖ ចុះពីក្មេងគាត់រត់ម៉ូតូឌុបដែរ?

ខ៖ គាត់រត់ម៉ូតូឌុបតាំងពីអើយមកម្ល៉េស

ក៖ ចុះគាត់ជាមនុស្សបែបណាដែរបង គាត់ស្លូត រឺមួយក៏កាចដែរបង?

ខ៖ ប៉ារបស់ខ្ញុំគាត់រៀងកាចតិចហើយនឹង

កៈ គាត់ស្លូតដែរណាបង?

ខៈ អត់ទេប៉ារបស់ខ្ញុំគាត់រៀងកាច

កៈ អូចុះម្តាយរបស់បងគាត់ស្លូតទេ?

ខៈ ម្តាយគាត់ស្លូតទេ

កៈ ចុះម្តាយរបស់បងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខៈ ម៉ែរបស់ខ្ញុំគាត់លក់បន្លែនឹង ខ្ញុំយកបន្លែគាត់លក់នឹង

កៈ ឥឡូវនឹងគាត់នៅតែលក់ដែរ?

ខៈ គាត់ចាស់ហើយឥឡូវនឹង

កៈ ប៉ុន្តែម្តាយរបស់បងគាត់នៅណាដែរបង?

ខៈ នេះគាត់នៅជួលផ្ទះគេនៅតា

កៈ អូនៅជាមួយបងមែនបង?

ខៈ អត់ទេគាត់នៅផ្សេងគាត់ជួលផ្ទះគេនៅ

កៈ ប៉ុន្តែគាត់លក់បន្លែយូរ ហើយ រឺក៏គាត់ទើបតែលក់?

ខៈ ទេគាត់លក់បន្លែយូរហើយគាត់លក់តាំងពីក្មេងហោស តាំងពីខ្ញុំនៅអាយុ18ឆ្នាំហោស

កៈ អូបាទបង
ចុះបងមានចងចាំសាច់រៀងអីកាលពីបងនៅជាមួយគាត់ហាសមានសាច់រឿងអីដែរបងគិតថាបងចងចាំហាស?

ខៈ បងនិយាយរួមទោបងលក់តែបន្លែទេ
ក្រោយពីបងឈប់លក់បន្លែបងធ្វើការងាររោងចក្រ

កៈ
ប៉ុន្តែបងមានចងចាំថាកាលពីបងនៅជាមួយឪពុកម្តាយរបស់បងនឹងបងធ្លាប់មានធ្វើអីគេខ្លះដែរទេបង?

ខ៖ បងអត់ដែរបានធ្វើអីទេ ដូចបងនិយាយប្រាប់អូនឯងចឹងថាបងលក់បន្លែបន្លុក ពេលដែរបងលក់បន្លែទៅបងឃើញម៉ែពិបាកក៏បងធ្វើការរោងចក្រទៅ

ក៖ អូចឹងហោសបង?

ខ៖ នឹងបានបងឈប់រៀនបងគិតថាម្ដាយរបស់បងអត់បានបងធ្វើការនៅរោងចក្រនឹង ពេលដែរបងឈប់លក់បន្លែទៅ និយាយរួមបងធ្វើការនៅរោងចក្រអាយុ17ឆ្នាំទេ

ក៖ ចុះឪពុករបស់បងគាត់មានធ្លាប់ពីប្រវត្តិគាត់កាលពីគាត់នៅក្មេងទៅបងទេ?

ខ៖ និយាយអោយចំទៅបងថាប្រវត្តិរបស់គាត់នឹងគាត់ធ្វើជាថៅកែទូក

ក៖ អូគាត់ធ្វើថៅកែទូកហោស?

ខ៖ គាត់ថៅកែទូក ប៉ុន្តែគាត់លិចទូក ចឹងគាត់ខាតអស់រាប់ម៉ឺនដុល្លាហោស ចឹងគាត់លក្ខណះថាគាត់ធ្លាក់ខ្លួនចឹង គាត់រត់តែម៉ូតូឌុបទេ កាលពីមុនគាត់មានប្រវត្តិធ្វើជាថៅកែទូក

ក៖ អូចឹងកាលពីមុនគាត់មានណាបង?

ខ៖ គាត់មានតែគាត់ក្រឡាបទូកទៅគាត់ក្រ

ក៖ ចឹងគាត់ធ្លាក់ខ្លួនហោស?

ខ៖ ចាគាត់ធ្លាក់ខ្លួននឹង

ក៖ ចុះម្ដាយរបស់បងគាត់មានធ្លាប់ប្រវត្តិគាត់កាលពីគាត់នៅក្មេងទេ?

ខ៖ អូកាលពីមុនម៉ែរបស់ខ្ញុំគាត់ថៅកែធ្យូង

ក៖ អូសុទ្ធតែថៅកែដូចគ្នា?

ខ៖ គាត់ថៅកែនិយាយអោយចំទៅគាត់ថៅកែប៉ារបស់ខ្ញុំគាត់ថៅកែឈើ ហើយម្ដាយរបស់ខ្ញុំគាត់ថៅកែធ្យូងនឹង គាត់ដឹកធ្យូងកាលណុងគាត់អាយុប្រហែលជា13-14ឆ្នាំ និយាយអោយចំទៅខ្ញុំកើតនៅលើកប៉ាល់នៅមុខវាំងទេ ពីព្រោះបងគ្មានផ្ទះសំបែងទេ

ក៖ ចុះម៉េចបានម្ដាយរបស់បងគាត់ធ្លាក់ខ្លួនដែរបង?

ខ៖ គាត់ធ្លាក់ខ្លួនដោយសារតែលិចទូក

ក៖ អត់ទេម្ដាយហាស?

ខ៖ គាត់លិចទូកប៉ារបស់ខ្ញុំមិនដឹកឈើមែនទេ
ហើយមិនជំនួញជួញដឹកធ្យូងម៉ែរបស់រាប់តោន
ដល់ពេលនឹងទៅមិនលិចទំនិញទាំងអស់គ្នា
ដល់ពេលដែរលិចទៅមនុស្សមិនស្លាប់ក្នុងទឹកច្រើន
ចឹងគឡាត់មិនខាតដោយសារតែគាត់លក់ដី លក់ផ្ទះសំបែង សងគេមិនគ្រប់ផងនឹង
នឹងចឹងបានគាត់ធ្លាក់ខ្លួនត្រង់នឹងឯងនឹង

ក៖ អូចុះបងមានចងចាំយាយតាខាងម្ដាយទេ ថាគាត់មានឈ្មោះអីចឹងហាស?

ខ៖ អូខ្ញុំអត់ដឹងទេ

ក៖ អត់ស្គាល់ឈ្មោះគាត់ទេណបង?

ខ៖ អត់ចាំទេពីព្រោះបងមិនទាន់កើតទេ បងមិនចាំឈ្មោះគាត់ទេ

ក៖ ចុះយាយតាខាងឪពុកនឹងបងអត់ចាំដែរ

ខ៖ បងអត់ចាំទេ
បងគ្រាន់តែដឹងថាឪពុករបស់បងគាត់ធ្វើថៅកែឈើនៅមុខវាំងប៉ុន្តែគាត់បានលិចកប៉ាល់
ហើយមានមនុស្សជាច្រើនស្លាប់ណាស់ គាត់ដឹកឈើ នឹងដឹកធ្យូងហើយលិចទៅបាត់ទៅ
យើងមានលទ្ធភាពណា មានតែយើងលក់របស់នឹងទៅសងគេនឹងរឿងនឹងវាចឹង

ក៖ ចឹងរឿងយាយតាខាងឪពុកគាត់មិនដែរប្រាប់ទេ?

ខ៖ បងអត់ដែរ ពួកគាតើមិនដែរប្រាប់ទេ

ក៖ អូពួកគាត់មិនដែរប្រាប់ទេណបង
ចុះក្រុមគ្រួសាររបស់បងមកនៅទីក្រុងភ្នំពេញនឹងយូរនៅបង?

ខ៖ យូរហើយនឹង ជាង10ឆ្នាំហើយនឹងហាស

ក៖ ជាង10ឆ្នាំណបង?

ខ៖ នឹងហើយតាំងពីបងអាយុ13-14ឆ្នាំ ឥឡូវបងអាយុ35ឆ្នាំហើយនឹងហាស

ក៖ ជាង20ឆ្នាំហើយបង ប៉ុន្តែនៅតែមួយកន្លែងរឺក៏មានការផ្លាស់ទីលំនៅរហូតដែរបង?

ខ៖ បងអត់ទេកាលពីមុនបងនៅនេះកន្លែងគេលក់បាយនេះវាដូរតែគ្នាទេ
បងនៅកន្លែងជួលផ្ទះគេនៅនេះទេនឹង

ក៖ ចឹងមានន័យថាកាលពីមុនបងនៅនោះ?

ខ៖ កាលមុនបងនៅនេះទេបងលក់ផ្ទះសំបែងខាតយកទៅសងគេអស់ទៅ

ក៖ ចុះបងមានសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសអត់បង?

ខ៖ បងអត់មានទេអូន

ក៖ អូបងប្អូនអីក៏អត់មានទាំងអស់ដែរ?

ខ៖ អត់មានទាំងអស់នឹង

ក៖ ចុះស្វាមីរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ គាត់មានឈ្មោះ ឈុន គុណ

ក៖ ចុះបងរៀបអាពាហ៍នៅថ្ងៃខែឆ្នាំណាដែរបងមានចងចាំទេ?

ខ៖ បងមិនបានការទេ បងបានតែសែនទេ

ក៖ អូបានសែន ប៉ុន្តែដូចជាពេលណាដែរបង?

ខ. បើនិយាយទៅវាយូរដែរហើយចឹងបងរៀងភ្លេចដែរហើយនឹង

ក៖ ដូចជាកូនរបស់បងធំជាងគេនឹងអាយុប៉ុន្មានដែរបង?

ខ៖ កូនបងអាយុ13ឆ្នាំហើយនឹង

ក៖ ពេលដែរបងសែនហើយបងមានកូនតែម្តងណាបង?

ខ៖ ចាបើនិយាយអោយចំទៅបងរៀបបានមួយខែ

ក៖ ចឹងបើនិយាយទៅវាថាប្រហែលជាង13ឆ្នាំហើយមែនទេ?

ខ៖ នឹងហើយវាជាង13-14ឆ្នាំហើយនឹង

ក៖
ចុះបងមានចងចាំថាពេលដែរបងរៀបចំសែននឹងប្តីរបស់មានមានជាជំនូនជូនទៅបងទេ?

ខ៖ អត់មានទេអូនពីព្រោះតែបងសែននឹងបងប្អូនរបស់គេមានទិញតែក្បាលជ្រូក
ហើយនឹងទា នឹងមាន់ទេដែរគេដាក់សែនអោយយើងនឹងហោសក្រៅពីនឹងអត់មានទេ

ក៖ ចុះបងអាចប្រាប់ខ្ញុំបានទេថាបងជួបជាមួយស្វាមីរបស់បងនៅពេលណា
ហើយហេតុអីបានជាបងស្រលាញ់គ្នាទេបង?

ខ៖ អូយយូរដែរនឹងអូនអើយតាំងពីបង
និយាយអោយចំទៅបងយកប្តីរបស់បងប្រហែលជាអាយុ21ឆ្នាំដែរបងយកគាត់នឹង

ក៖ បាទបងដូចជាបងស្រលាញ់គ្នាពេលណាបានបងយកគ្នានឹង?

ខ៖
នឹងហើយនិយាយទៅថាបងអាយុ20ឆ្នាំគត់ចុះដែរបងស្រលាញ់គ្នានៅកំពង់សោមហោស
ណា មិនមែននៅខេត្តនឹងទេនៅខេត្តកំពង់សោមកំពតហោស

ក៖ ប៉ុន្តែបងស្រលាញ់គ្នាប៉ុន្មានឆ្នាំដែរបានបងយកគ្នាចឹងហាស?

ខ៖ អូបងស្រលាញ់គ្នាប្រហែលជា2-3ឆ្នាំហោសបានបងយកគ្នាជាអនាគត់កូនចៅហោស

ក៖ ចុះបងចេះអាន រឺក៏បងចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខ៖ ទេបងមិនសូវជាចំណាប់ទេ ពីព្រោះបងរៀនបានត្រឹមថ្នាក់ទី4និយាយអោយចំទៅនឹង

ក៖ បងរៀនបានថ្នាក់ទី4ណាបង
ចុះកាលពីបងរៀនបានថ្នាក់ទី4នឹងតើបងរៀននៅសាលាបឋមសិក្សានៅណាដែរបង?

ខ៖ អូនេះនៅវត្តដំឡូង

ក៖ អូនៅវត្តដំឡូងហោសបង
ចុះកាលពីបងរៀននឹងតើបងរៀននៅសាលាបឋមសិក្សាឈ្មោះអីគេដែរបង?

ខ៖ អូឈ្មោះសាលានរោត្តម

កៈ អូនៅសាលានពោត្តមហោសបង នៅភ្នំពេញយើងនឹងហោសបង?

ខៈ នៅភ្នំពេញយើងនឹងឯងនឹង

កៈ ចុះបងមានប្តូរសាលាទៅតអត់បង រឺក៏បងរៀនតែនៅនឹងទេ?

ខៈ បងអត់ដូរទេបងរៀនតែនៅនឹងរហូតបងឈប់ទៅ

កៈ
អូបាទចុះបងមានមិត្តភក្តិស្និទ្ធិស្នាលណាដែរធំធាត់មកជាមួយគ្នាអត់តាំងពីក្មេងៗហាស?

ខៈ បងមិនដែរមានទេអូន បងមានតែម្នាក់ឯងទេ

កៈ ចុះកាលនៅក្មេងៗហាស កាលពីនៅរៀនហាស?

ខៈ បងអត់ដែរទេ បងមិនសូវដែររវីរវល់មានមិត្តភក្តិទេ
និយាយអោយចំទៅបងចេះដូចគេទេពេលដែរបងចេញពីរៀនបងទៅផ្ទះម្តាយរបស់បងហើយនឹង

កៈ អូប៉ុន្តែកាលពីនៅរៀនបងមានមិត្តភក្តិធម្មតាតាហីបង?

ខៈ បងអត់ដែរមានទេប្អូន
និយាយអោយចំទៅដូចថាបងអត់សូវចេះរញ៉េរញ៉ៃទេបងដឹងតែរៀនពេលមកពីរៀនបងទៅផ្ទះហើយនឹង

កៈ ចុះដូចជាបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?

ខៈ បងអត់ចេះអីទេបងចេះតែខ្មែរទេ ពីព្រោះបងរៀនបានថ្នាក់ទី4នឹង

កៈ ចឹងភាសាអង់គ្លេស ថៃ វៀតណាម?

ខៈ និយាយទៅបងអត់ចេះទេ

កៈ អូបាទបងចុះបងមានធ្លាប់ទៅធ្វការនៅវាលស្រែទេបង?

ខៈ បើនិយាយពីស្រែបងអត់ទេបងធ្លាប់តែធ្វើការនៅភ្នំពេញ

កៈ បងធ្វើការនៅភ្នំពេញ ចុះបងធ្វើអីនៅភ្នំពេញនឹង?

ខ៖ បងធ្វើដេរខោអាវ ពោយ

ក៖ ដេរខោអាវពោយហោសបង?

ខ៖ ចាហើយនឹងកាត់ព្រុយ កាត់អីនឹង

ក៖ ចុះកាលណុងបងនៅប៉ុណ្ណាទៅ?

ខ៖ ដូចបងប្រាប់ចឹងថាបងអាយុប្រហែលជា13-14ឆ្នាំទេបងឈប់លក់បន្លែ បងមកធ្វើការនៅរោងចក្រប៉ុន្តែបងប្រាប់ថាបងអាយុ18ឆ្នាំប៉ុន្តែគេអត់ជឿបងទេ និយាយអោយចទៅបងទើបតែអាយុ13-14ឆ្នាំទេ នឹងបងតស៊ូបងឈប់រៀននឹងហាស បងឈប់រៀបថ្នាក់ទី4នឹងហោស

ក៖ ចុះបងដេរខោអាវនឹងអស់រយះពេលប៉ុន្មានដែរទៅ?

ខ៖ បងដេរដែរហោសវាចូលប្រហែលជា6-7ឆ្នាំដែរនឹងហាសបានបងឈប់នឹង

ក៖ ប៉ុន្តែពេលណុងបងដេរស៊ីភាគរយហី?

ខ៖ ចាៗទៅវាស៊ីភាគរយដែរនឹងប្រាក់ខែដូចថា15ម៉ឺនដែរនឹងបងដេរ

ក៖ ចុះកាលណុងឆ្នាំប៉ុន្តែដែរទៅបង?

ខ៖ វាយូរដែរនឹងអូនបងអាយុ14-15ឆ្នាំដែរនឹង

ក៖ វាជាង20ឆ្នាំចឹងប្រហែលជាឆ្នាំ1990ជាងណាបង?

ខ៖ និយាយទៅប្រាក់ខែ20ម៉ឺនលុយធំហើយណា លុយនឹងចាយធំជាងលុយយើងឥឡូវនឹង មិនដូចឥឡូវនឹងប្រាក់ខែ400-500ទេ កាលពីមុនលុយ20ម៉ឺនវាធំហើយណា បងដេរមួយថ្ងៃបាន14-15ម៉ឺនទេណាតែប៉ុណ្ណឹង

ក៖ ប៉ុន្តែបងរកលុយបានច្រើនដែរតាហីបង?

ខ៖
អត់ទេអត់បានទេទើបតែយើងឥឡូវនឹងទេដែរមានការថែមម៉ោងថែមអីហោសពីមុនគ្មានការថែមម៉ោងអីទេនឹងបានតែប៉ុណ្ណឹងប្រាក់ខែ ហើយចេញម៉ោង6ទៀតហោស អាចនឹងទល់ភ្លឺថែមទៀតក៏មានដែរនឹង

កៈ ចុះបន្ទាប់ពីបងធ្វើអានឹងហើយបងធ្វើអីគេទៀតទៅ បន្ទាប់ពីបងដេរនឹង?

ខៈ បងអត់ធ្វើអីទេ បន្ទាប់មកបងរកអេតចាយ

កៈ បងរើសអេតចាយនៅនឹង?

ខៈ បងរើសអេតចាយ បងដើររើសអេតចាយ

កៈ ហើយបានបងលក់លាសតែម្តង?

ខៈ ចាបងលក់លាស

កៈ រហូតដល់ពេលណុងបានបងលក់លាសដល់ឥឡូវនឹង?

ខៈ ចាហើយបងលក់លាសដល់ឥឡូវ

កៈ អូបាទបងចុះបងធ្លាប់បើកអាជីវកម្មអីទេបង?

ខៈ បងគ្មានដែរមានអាជីវកម្មអីទេ ពីព្រោះបងគ្មានលទ្ធភាពអីទេ

កៈ ជាលក្ខណៈខ្នាតតូចអី រឺជាគ្រួសារអីមានទេបង?

ខៈ បងអត់សោះតែម្តងនឹង

កៈ អត់ទេណាបង?

ខៈ បងអត់សោះតែម្តង

កៈ ចុះបងមានធ្លាប់ចិញ្ចឹមមាន់ ទា គោ ក្របីអីទេបង?

ខៈ បងអត់ដែរទេ

កៈ និយាយរួមបងនៅតែភ្នំពេញនឹងទេ?

ខៈ បងជួលផ្ទះគេនឹង ពីមុនបងមានផ្ទះឥឡូវនឹងបងលក់ផ្ទះអស់ហើយ

កៈ ប៉ុន្តែយើងពិបាករកកន្លែងចិញ្ចឹមទេណាបង?

ខៈ ចាបងពិបាករកកន្លែង

កៈ ចុះបងគិតថាបងធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់បងហាស?

ខ៖ ដូចបងនិយាយចឹងហាស បងមានតែលក់លាសទេ
បើមិនលក់លាសទេគ្មានអីជាចិញ្ចឹមខ្លួនឯងទេ មានតែលក់លាសទេ
ចុះមេយចឹងលក់លាសម៉េចនឹងកើតទៅ

ក៖ អូចុះក្រុមគ្រួសាររបស់បងលក់លាសដែរ?

ខ៖ មានតែពីរនាក់ប្ដីប្រពន្ធនឹងហើយកូនរៀន
ហើយកូនអត់មានលុយអោយទៅរៀនទៀតនឹង

ក៖ អូប្ដីរបស់បងលក់លាសដែរ?

ខ៖ ចាលក់ទាំងប្ដីទាំងប្រពន្ធនឹង

ក៖ អូលក់លាសទាំងពីរនាក់នឹងហោសបង?

ខ៖ ចាហើយកូនមានតែទៅរៀនពីរបីបួននាក់នឹងឯងនឹង
មានណាអត់មានលុយអោយកូនទៅរៀនផងនឹងចឹងហាស

ក៖
ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្ដូរអីគេខ្លះដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ មានផ្លាស់ប្ដូរអីមានតែលក់លាសនឹង

ក៖ កាលពីក្មេងមានធ្វើអីគេ ហើយឥឡូវនឹងធ្វើអីគេចឹងហាស?

ខ៖ កាលពីក្មេងបងនិយាយប្រាប់ថាបងលក់ជីជ្រូក ក្រូចឆ្មា
បងចេញពីនឹងបងទិញអេតចាយ ចេញពីទិញអេតចាយបងធ្វើមុខរបរនឹង

ក៖ បងលក់ជីជ្រូកក្រូចឆ្មានឹងបងមានលក់ត្រកួនអីដែរតាហីបង?

ខ៖ អត់ទេបងលក់តែជីជ្រូកក្រូចឆ្មា កន្ត្រៀតចង្កេះទេគេដេញរហូតនឹង

ក៖ អូបងទៅលក់នៅផ្សារណាទៅបង?

ខ៖ បងទៅលក់នៅផ្សារចាស់

ក៖ អូនៅផ្សារចាស់យើងហោសចុះបងលក់ប៉ុន្មានឆ្នាំទៅបានបងឈប់លក់ហាស

ខ៖ អូបងលក់ប្រហែលជាចូល2ឆ្នាំដែរនឹងហាស បានរកស៊ីចិញ្ចឹមម្ដាយនឹង

ក៖ ប៉ុន្តែបងលក់នឹងលក្ខណៈជាច្រើនរឺមួយក៏លក់តិចបង?

ខ៖ បងលក់តិចៗនឹងអូន

ក៖ លក់តែមួយកញ្ជ្រែងអីទេណាបង?

ខ៖ លក់តែមួយកញ្ជ្រែងតែមួយកន្ត្រៀតចង្កេះនឹង ថាជីជ្រូកដូចថាមាន15ដុំចុះនឹង

ក៖ ជាមួយនឹងក្រូចឆ្មាដែរណាបង?

ខ៖ នឹងហើយបងលីជីជ្រូកនឹងក្រូចឆ្មានឹងឯង

ក៖ អូពេលនឹងចំនេញច្រើនរឺមួយក៏តិចដែរបង?

ខ៖ អូមិនចំនេញប៉ុន្មានដែរទេអូន

ក៖ ដោយសារតែវាមានតិចដែរណាបង?

ខ៖ អូនឯងដឹងស្រាប់ហើយឆ្នាំនឹងហោស
មិនមែនស្រួលលក់ទេតិចប៉ូលីសដេញៗហោសដូចថារកស៊ីមិនដូចគេធ្វើអីទេតែប៉ូលីសដេញរត់ហើយ ដូចថាយើងដាក់ចង្កេះដឹងស្រាប់ហើយតែប៉ូលីសដេញរត់ហើយនឹង

ក៖ ចុះបងចូលចិត្តម្ហូបអីតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ ថាដូចបងនិយាយចឹងម្ហូបអីក៏បងហូបដែរនឹង

ក៖ ប៉ុន្តែអ្វីដែរបងគិតថាបងចូលចិត្តតែម្តងហាស?

ខ៖ បងចូលចិត្តថា

ក៖ លក្ខណៈថាស្ងោរ ឆា ចៀនអីចឹងហាស?

ខ៖ និយាយទៅបងចូលចិត្តតែឆាមួយមុខទេ
ឆាតែត្រកួនទេដែរបងហូបបានក្រៅនឹងបងហូបមិនបានទេនឹង

ក៖ បងចូលចិត្តនឹងជាងគេ?

ខ៖ នឹងហើយឆាបានតែប៉ុណ្ណឹង ពីព្រោះបងកំរហូបសម្លអីណាស់មិនងាយទេនឹង

កៈ
ចុះបងគិតថាល្បែងប្រជាប្រិយ៍អីដែរបងចូលចិត្តលេងហាសតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង ដូចជាល្បែងចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែងអីហាស?

ខៈ ថាល្បែងបងមិនសូវចំណូលទេ

កៈ អូល្បែងតាមវត្តអីក៏បងអត់ចូលចិត្តដែរ?

ខៈ បងកំរចូលចិត្តហាសរឿងល្បែងអស់នឹងពីព្រោះអីនឹងជីវភាពយើងវាអត់
គិតថាល្បែងសប្បាយបងមិនសូវជាចំណូលដូចគេទេ
បងមិនចំណូលទេនិយាយអោយត្រង់

កៈ អូបាទបងចុះបើនិយាយពីច្រើងវិញបង?

ខៈ បើច្រៀងបានចូលចិត្តច្រៀងមែន
បើច្រៀងទាល់តែមាននេះបានបងច្រៀងបើមិនកើតក៏បងមិនច្រៀងដែរនឹង
បងចូលចិត្តច្រៀងហាណា ក្រៅនឹងបងមិនចេះរញ៉ូរញ៉ៃទេ

កៈ ប៉ុន្តែបងចូលចិត្តស្តាប់បទចំរៀងដែរណាបង?

ខៈ អូភាសាបទចំរៀងបងចេះទាំងអស់នឹងពីដើមតែឥឡូវនឹងបងសូវចេះទេ
តែបើនិយាយអោយចំទៅឥឡូវនឹងក៏បងច្រៀងលែងកើតដែរពីព្រោះថាចំណាស់នឹងហើយនឹង មិនមែនដូចយើងពីមុនទេណា ពីមុនយើងច្រៀងកើតតែឥឡូវនឹងមិនបានទេ

កៈ ចុះកាលពីបងច្រៀងនឹងជាលក្ខណៈបទបុរាណរឺបទសម័យដែរបង?

ខៈ បងចេះតែបទពីដើមទេ

កៈ អត់ដែរច្រៀងបទសម័យទេណាបង អត់សូវចូលចិត្តណាបង?

ខៈ អត់ដែរទេ អត់ជំនាញនិយាយអោយចំទៅអត់ចេះតែម្តងបទឥលូវនឹង
បទពីដើមបងចេះតែបទឥលូវនឹងបងអត់ចេះទេ

កៈ ចុះបងតាំងពីក្មេងរហូតមកដល់ពេលនេះហាស
បងគិតថាមានបងប្អូនរបស់បងនាដែរគេចេះលេងឧបករណ៍ភ្លេងទេ?

ខៈ បងប្អូនរបស់បងអត់មានទេ

កៈ បទភ្លេងខ្មែរក៏អត់មានដែរណាបង?

ខៈ អត់មានទេ

កៈ អូបាទបង
ចុះបងគិតថាផ្ទះរបស់បងមានលក្ខណៈបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខៈ លក្ខណៈបងប្អូនរបស់ពិបាកណាស់

កៈ ផ្ទះរបស់បងកាលពីតូចនឹងយ៉ាងម៉េចដែរបង?

ខៈ ផ្ទះបងកាលពីតូចក៏ពិបាកដែរអូនអើយមានតូចដែរនឹង
វាពិបាករកណាស់អូនអើយវាមិនស្រួលដូចគេទេគិតទៅបងអាយុ7-8ឆ្នាំបងលក់ហើយ
ហើយបងជួលគេរហូតដល់18ឆ្នាំនឹងបងជួលគេរហូតនឹង
ពីព្រោះបងលក់ផ្ទះលក់អីដើម្បីសងគេពេលដែរប៉ារបស់លិចទូកនឹងសងគេអស់ហើយ

កៈ ចុះកាលពីបងនៅក្មេងប៉ុននេះនឹងដូចជាផ្ទហបងជាផ្ទះឈើរឺក៏ផ្ទះថ្មដែរបង?

ខៈ និយាយអោយចំទៅកាលពីបងលក្ខណៈប៉ុននេះនឹងជាផ្ទះថ្ម

កៈ ផ្ទះថ្មហោស ចុះកាលពីបងនឹងនរណាគេជាអ្នកសាងសងផ្ទះបងដែរ?

ខ. ឪពុកម្ដាយរបស់បង

កៈ អូបាទជួលគេអោយធ្វើណាបង?

ខៈ ចាជួលគេ

កៈ អូបាទចុះឪពុករបស់បងគាត់ចេះធ្វើផ្ទះទេ?

ខៈ គាត់អត់ចេះទេគាត់ហៅជាងទៅធ្វើនឹង
នឹងរបៀបបងលក់ផ្ទះចាស់យកទៅធ្វើផ្ទះថ្មីចឹងហាស

កៈ អូប៉ុន្តែបងមានដឹងថាផ្ទះរបស់បងធ្វើនឹងគេមានប្រើសំភារៈអីគេខ្លះសំរាប់ធ្វើអត់បង?

ខៈ ឥដ្ឋការ៉ូអូន

កៈ ឥដ្ឋការ៉ូណាបង មានស៊ីម៉ង់អី?

ខៈ រៀបផ្ទះគេនឹងហាស

កៈ
ចុះបងគិតថាជំនាញអីដែរបងគិតថាបងចេះស្ទាត់តាំងពីដើមរហូតមកដល់ពេលនេះហាស?

ខៈ ជំនាញបងហោស?

កៈ បងគិតថាបងចេះធ្វើអីគេដែរបង?

ខៈ និយាយអោយចំទៅជំនាញបងអីក៏បងលក់ដែរនឹង
ស្អីក៏បងរកដែរបងមិនគិតថាជំនាញណាអីជំនាញណាទេនឹង
ស្អីក៏បងរកដែរមានស្អីបងលក់នឹង អោយបងរកអេតចាយបងរកអេតចាយ
លក់លាសបងលក់បានបងលក់ និយាយទៅមិនថាជំនាញអីក៏បងរកបានដែរនឹង

កៈ ចុះបងឪពុកម្តាយរបស់បងគាត់មានធ្លាប់បង្រៀនពីជំនាញអីមួយទៅបងទេ?

ខៈ គាត់អត់ទេ

កៈ ចុះធ្វើម្ហូបអីក៏បងអត់ដែរដែល?

ខៈ ម្ហូបបងអត់ទេ បងជំនាញខ្លួនឯងនឹងតែបងក៏មិនជំនាញធ្វើម្ហូបដូចគេដែរបានធម្មតានឹង
មិនដូចប្តីរបស់បងទេ

កៈ ចុះដូចលក្ខណះថាវេញល្ហី ក្លូរស្កុរអីបងអត់ចេះទេណាបង?

ខៈ អើរបងមិនសូវជំនាញទេ

កៈ ធ្វើផ្តៅធ្វើអី

ខៈ បងមិនសូវជំនាញទេ ដូចបងនិយាយចឹងបងមិនសូវជំនាញទេ

កៈ អូបាទបង ចុះបងអាចប្រាប់ពីពេលដែរបងលំបាកបានទេ?

ខៈ អូនិយាយអោយចំទៅបងពិបាកតាំងពីបងអាយុ12-13ឆ្នាំហោស
បងពិបាកតាំងពីបងធ្វើការនៅរោងចក្រហោស បងចេញពីលក់លាសហាស
បងលក់ក្រូចឆ្មាជីជ្រួកម៉ូតូបុកហាស នឹងបងតស៊ូតាំងពីនឹងមករហូតនឹងឯង

កៈ អូចឹងហោសបង?

ខៈ ដល់បងដល់ថ្នាក់យកប្តីឈប់បីលក់ជីនឹង ឃើញម៉ែពិបាកបងចូលធ្វើការនៅរោងចក្រ
នឹងយើងឈប់រៀនកាលពីយើងនៅថ្នាក់ទី4ហាស
ឃើញម៉ែឪពិបាកដល់ពេលដែរធ្វើការហើយ
អនាគត់បងនៅវែងឆ្ងាយបងមកយកប្តីទៅបងទិញអេតចាយ
គាត់តៅធ្វើសំណង់បងទិញអែតចាយ
ដល់ពេលដែរបងឃើញគេរកបានអាលាសនេះក៏បងឈប់រកអេតចាយក៏បងមកលក់លាស
នឹងហាស នឹងចុងក្រោយបងលក់លាសនឹងអនាគត់បងលក់លាសនឹងហាស

កៈ ចុះបងគិតថានៅពេលដែរឪពុកម្តាយរបស់បងលិចទូកនឹង
បងគិតថាបងមានការលំបាកអីគេខ្លះដែរទៅបង?

ខៈ បងពិបាកណាស់អូន កាលពីគាត់លិចទូកដំបូងនឹង
និយាយអោយចំទៅមនុស្សក៏ស្លាប់បងក៏រកលុយមកអត់ទាន់ទៀត
ចឹងបងលក់ផ្ទះជួយគ្រួសាររបស់គេដែរលិចទូកស្លាប់នឹង
យើងលក់ផ្ទះនឹងសង់គេទៅណាស់

កៈ បាទបងយើងជួយគេតិចៗហាសណាស់បង?

ខៈ នឹងហើយយើងជួយគេទៅ យើងក៏មើលមិនឃើញថាទូកនឹងលិចដែរចឹងហាស
ហើយគោលបំណងក៏មិនដឹងថាលិចដែរចឹងហាស
ចឹងយើងជួយធ្វើបុណ្យធ្វើទានអោយគេទៅ ធ្វើម៉េចយើងក៏មិនចង់អោយលិចដែរនឹង

កៈ យើងខាតទ្រព្យសម្បត្តិច្រៀនហាសណបង?

ខៈ ហឺអស់ច្រើនដែរនឹងអូន មិនអស់តិចទេអូន និយាយរួមឈើ ធ្យូង លិចទាំងអស់
ហើយមនុស្សនឹងមិនស្លាប់តិចទៀត ស្លាប់4-5-6នាក់ហោសអ្នកស្លាប់នឹង

កៈ នៅកណ្តាលទន្លេនឹងតែម្តងហោសបង?

ខៈ នៅកណ្តាលទន្លេអូនដោយសារតែលិច

កៈ ទន្លេនឹងមុខវាំងយើងនឹងហោសបង?

ខ៖ ទន្លេមុខវាំងនឹងលិចនឹងហើយយើងជួយណាទាន់
បើលិចហើយនឹងយើងជួយក៏អត់ទាន់ដែរនឹង
ចឹងមានតែយើងជួយធ្វើបុណ្យទ្រព្យសម្បត្តិយើងនឹងជួយគ្នាទៅមិនតិចគ្នាទេនឹង

ក៖ បាទបងចុះបងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរបង?

ខ៖ អូបងពិបាកតាំងពីតូចហោស ពិបាកតាំងពីរកស៊ីឃើញម៉ែឪពិបាកចឹង
ដល់ពេលដែរបានអាយុ14-15ឆ្នាំឃើញម៉ែឪពិបាកពេក
សុខចិត្តពិបាកខ្លួនឯងធ្វើការរោងចក្រ ម្តាយវៃសឹងស្លាប់ហើយឈប់រៀនហោស
ខ្ញុំមានតែប៉ុណ្ណឹងឯង

ក៖
ចុះបងគិតថាពេលណាដែរបងគិតថាជាពេលសប្បាយនៅក្នុងឆាកជីវិតរបស់បងហាស?

ខ៖ អើរបើសប្បាយនឹងមិនសប្បាយទេអូន
បងមិនសប្បាយទេមានតែពិបាកចិត្តពេលដែរឃើញឪពុកម្តាយជំពាក់គេនឹង

ក៖ ចុះកាលពីបងជួបប្តីរបស់បងដំបូង បងគិតថាសប្បាយទេ?

ខ៖ បងជួបប្តីរបស់បងថារឿងសប្បាយៗហើយតែពេលដែរថារយះពេលដែរ1-
2ឆ្នាំទៅដល់ពេលឃើញម៉ែឪពិបាកចិត្តលែងសប្បាយហើយនឹង
ខ្ញុំមិនចោលម៉ែឪទេពេលដែរម៉ែឪអត់ទេ

ក៖ ចិញ្ចឹមមានន័យថាពេលដែរបងសប្បាយពេលដែរបងជួបប្តីរបស់បងដំបូងហោសបង?

ខ៖ នឹងហើយនឹងយើងចេះតែសប្បាយចិត្តហើយ
ដល់ពេលយើងឃើញឪពុកម្តាយរបស់យើងជំពាក់គេក៏យើងសប្បាយមិនកើតដែរនឹង

ក៖ បាទបងចឹងហើយ?

ខ៖ នឹងវាត្រូវហើយនឹង

ក៖ ចុះបងធ្លាប់មានក្តីសង្ឃឹមតាំងពីក្មេងរហូតមកដល់ពេលនេះទេ
គិតថាបងចង់ធ្វើអីមួយចឹងហាស?

ខ៖
ថាបងសំខាន់ចេះថាបងមានប៉ុណ្ណឹងសំខាន់បងមានផ្ទះអោយម្ដាយរបស់នៅនឹងសង្ឃមថា
លក់លាសទៅសង្ឃឹមថាមានផ្ទះអោយម្ដាយនៅចឹងទៅណាវាគ្រាន់ដែរ
បើយើងជំពាក់គេយើងត្រូវសងគេ
គ្រាន់តែថាម្ដាយនៅមានលុយខ្វះខាតអីស្រួលនិយាយគ្នាទេ
អានឹងវាចឹងសំខាន់មានផ្ទះមានអីនៅទៅទាន់ម្ដាយនៅរស់

ក៖ ចុះបងមានធ្លាប់មានក្ដីស្រម៉ៃថាពេលដែរបងធំឡើងបងចង់ធ្វើអីគេទៅ?

ខ៖ បងមិនចង់មានក្ដីស្រម៉ៃអស់នឹងទេ
បងគ្រាន់តែមានក្ដីស្រម៉ៃថាសង្ឃឹមថាឪពុកម្ដាយនៅរស់ទៅបានហើយនឹង

ក៖ សូម្បីតែចង់ធ្វើជាគ្រូបង្រៀនក៏មិនចង់ដែរ?

ខ៖ អូបងមិនចង់ធ្វើទេ សំខាន់អោយបងរកបាន ហើយម្ដាយរបស់បងនៅរស់នឹង

ក៖ សំខាន់បងចង់អោយនៅជួបជុំក្រុមគ្រួសារណាបង?

ខ៖ ជួបជុំក្រុមគ្រួសារ

ក៖ ហើយអត់ជំពាក់បំណុងគេណាបង?

ខ៖ នឹងហើយវាចឹងយើងរាល់ថ្ងៃមិនរកដោយសារតែចឹងមិនត្រូវការជំពាក់បំណុងគេ
ហើយម្ដាយមានផ្ទះនឹងទៅ

ក៖
ចឹងសំខាន់អោយតែយើងមិនជំពាក់បំណុលគេទោះយើងនៅជួលគេក៏មិនអីដែរណាបង?

ខ៖ នឹងហើយវាចឹងយើងជួលគេ កុំអោយជំពាក់បំណុលទៅ
យើងចង់ធ្វើផ្ទះខ្ទមនៅក៏វាស្រួលដែរនឹង

ក៖
ចឹងជាចុងក្រោយបោចង់អោយបងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយបងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរបង?

ខ៖ ផ្តាំថាបើអត់ពីម្តាយឪពុកទៅដូចខ្ញុំមិនបាច់ថាកូន
ធ្វើម៉េចអោយតែរៀនបានចង់សញ្ញាប័ត្រទៅបើម្តាយអត់
រៀនមិនបានថ្នាក់ខ្ពស់អោយតែកូនរៀនបានថ្នាក់ខ្ពស់ទៅនឹងវាចឹង
តែអនាគត់ទៅបើវាមិនចេះគិតខ្លួនវាមិនដឹងថាធ្វើយ៉ាងម៉េចដែរនឹងឪពុកម្តាយជួយជ្រុំជ្រែង
អោយអស់ហើយ

ក៖ មានអីចង់ផ្តែផ្តាំទៀតអត់បង?

ខ៖ នឹងរបស់កូនទេសំខាន់លើសមត្ថភាពរបស់ពួកវាទេ
បើវាអសមត្ថភាពរកខ្លួនវាមិនដឹងជួយវាយ៉ាងម៉េចដែរនឹង បើយើងបានជួយវាតែប៉ុណ្ណឹងទេ
រកមួយគ្រាតែប៉ុណ្ណឹងទេ

ក៖
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនដែរបងបានចំណាយដូចជាចំណាយពេលដើម្បីអោយខ្ញុំ
បានពិភាក្សាពីប្រវត្តិរបស់បងជាមួយនឹងបងហាស
ហើយដូចជាខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាហាសបង
ដើម្បីដំកុលទុកអោយបងចឹងហាស

ខ៖ ចាបងដឹងតា

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបង ហើយជូនពរបងអោយមានសុភមង្គល
នឹងរកស៊ីមានបានចឹងហាសបង បាទអរគុណច្រើនបង៕៕៕